9
2019
VOL. 168

# Living the LOTUS

## Buddhism in Everyday Life




**Living the Lotus**
**Vol. 168 (September 2019)**

Senior Editor: Koichi Saito
Editor: Kensuke Suzuki
Copy Editor: Penn Setharin
*Living the Lotus* is published monthly by Rissho Kosei-kai International, Fumon Media Center, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីស្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីស្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីស្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.



*President's Message*

# ដោយសារតែភាពខុសគ្នានោះហើយ

ព្រះសង្ឃនីវ៉ាណូ និជិកុ
ព្រះប្រធានរីហ្សូកូសេកៃ

## ឱ្យមានចិត្តស្រឡាញ់មនុស្សគ្រប់គ្នា

នៅក្នុងសៀវភៅ『កម្រងកំណាព្យសម័យបុរាណនិងសម័យថ្មីរបស់ជប៉ុន』(Kokinwakashu) លោកឃីណុ ទ្សឺរ៉ាយុគី បានបន្សល់នូវកំណាព្យស្នេហារបស់លោកមួយដែលមានសេចក្តីដូចតទៅនេះ ៖<ដូចជាព្រះពាយដែលផាយផាត់ទៅគ្រប់ទិសទីដូច្នេះដែរ, មនុស្សរលឹកសង្សារដែលខ្លួនមិនដែលទាំងឃើញមុខផង។នេះហើយជាចិត្តមនុស្សទូទៅក្នុងលោកនោះ>។

បើគិតថាជាកំណាព្យស្នេហាក៏អាចថាបាន។ក៏ប៉ុន្តែបើយោងទៅតាមការបកស្រាយរបស់អ្នកអក្សរសាស្ត្រម្នាក់ កំណាព្យនេះ អ្នកអានធម្មតាមិនសូវជាគិតដល់សច្ចធម៌ដែលបង្កប់នៅខាងក្នុងនោះឡើយ។សច្ចធម៌នោះគឺថា នៅឯជម្រៅបេះដូងរបស់មនុស្សម្នាក់ៗតែងតែមានសេចក្តីស្នេហា សេចក្តីអាណិតមេត្តាទៅលើសព្វសត្វដែលមានជីវិតរស់នៅលើលោកនេះ។

ក៏ប៉ុន្តែនៅក្នុងការពិតជាក់ស្តែងយើងឃើញមានស្ថានភាពជាច្រើនដែលផ្ទុយពីអ្វីដែលនិយាយពីលើមកនេះ។ ដោយសារតែមូលហេតុថាគំនិត,ឬទស្សនៈឬការមើលទៅអ្វីមួយមិនដូចគ្នា,ជម្លោះប្រកែកហែកហួរ,បែកបាក់គ្នាតែងតែកើតមានឡើង។បើប្រទេសនិងប្រទេសក៏កើតជាការផ្តាច់ទំនាក់ទំនងការទូតឬក៏ផ្ទុះភ្លើងសង្គ្រាមរវាងគ្នានិងគ្នា។ជាពិសេសដែលគួរឱ្យសោកស្តាយនោះគឺមានបញ្ហាវិវាទដោយសារតែរឿងសាសនា។ មានមនុស្សជាច្រើនដែលមិនអាចទទួលបាននូវអ្វីៗដែលខុសពីគំនិតដែលខ្លួនគិត,ហើយក៏តាំងកើតទុក្ខបុកម្នេញរហូតដល់កើតទៅជាជម្លោះដែលគ្មានផលប្រយោជន៍អ្វីទាល់តែសោះ។

នៅក្នុងស្ថានភាពបែបនេះវិធីដោះស្រាយបញ្ហាដែលស្រួលជាងគេមានតែមួយគត់ គឺថាយើងត្រូវតែគិតនិងដឹងថាមនុស្សម្នាក់ៗមិនដូចគ្នាទេ គិតក៏ខុសគ្នា,រូបរាងក៏ខុសគ្នា,ហើយទទួលយកការពិតនេះកុំចចេស។ដើម្បីឱ្យអាចទទួលយកបានគឺដំបូងឡើយមានតែដាស់មនសិកាដែលកំពុងដេកលក់ឱ្យភ្ញាក់ឡើងដឹងថា <នៅឯក្នុងជម្រៅចិត្តរបស់ខ្ញុំក៏មានសេចក្តីស្រឡាញ់មេត្តាករុណាចំពោះមនុស្សសត្វទាំងអស់ដូចគេដូចឯងដែរ> ។ដល់តែដូច្នេះទៅយើងក៏អាចដឹងនិងមើលឃើញនូវសារសំខាន់និងតម្លៃនៃភាពខុសគ្នារបស់យើងនិងគេថាវាសំខាន់និងមានតម្លៃប៉ុនណាហើយ។

## ន័យនិងសារសំខាន់នៃ <ភាពខុសគ្នា>

យើងម្នាក់ៗកើតមកលើលោកនេះបានដោយសារមូលហេតុនិងឧបនិស្ស័យផ្សេងៗគ្នា។លុះបានយោនកំណើតមកហើយមនុស្សម្នាក់ៗត្រូវបានចិញ្ចឹមឱ្យធំដោយឧបនិស្ស័យដោយឡែកនីមួយៗហើយក៏កកើតបានជាអត្តសញ្ញាណមួយដែលគេហៅថា <អាត្មាអញ>។

ដូច្នេះកុំថាឡើយដល់ទៅនិយាយពីភាពខុសគ្នានៃពូជសាសន៍ រូបសម្ផស្ស សូម្បីតែការគិតឃើញ ការយល់ឃើញឬក៏ការមើលឃើញទៅលើអ្វីឃើញខុសគ្នានោះក៏វាគ្មានអ្វីជាការចម្លែកសោះឡើយ។បើយើងយកលេសថាអ្នកខាងនោះគេគិតខុសពីយើងហើយ

យើងយកលេសនោះទៅធ្វើជាមូលហេតុនៃទំនាស់ឬក៏ដកគេចេញពីក្រុមនោះវាមិនខុសអ្វីពីបដិសេធអត្តសញ្ញាណរបស់ខ្លួនយើងនោះឡើយ។

នៅក្នុងពិភពសាសនាក៏បែបនោះដែរ។ ជាការធម្មតាទេដែលមនុស្សម្នាក់ៗមានឧបនិស្ស័យឈានជើងចូលទៅក្នុងផ្លូវដែលបានត្រូវសាសនាផ្សេងៗគ្នាជួយស្រោចស្រង់ឱ្យចាកផុតពីទុក្ខវេទនា។មានអ្នកខ្លះត្រូវបានស្រោចស្រង់ដោយសាសនាព្រះគ្រឹស្ត,អ្នកខ្លះទៀតទៅដោយសាសនាអ៊ីស្លាម ,អ្នកខ្លះទៀតទៅដោយសាសនាព្រះពុទ្ធ។គឺមានន័យថានៅលើលោកយើងនេះមានសាសនាជាច្រើនដែលប្រៀនប្រដៅណែនាំមនុស្សដែលប្រាថ្នានូវសេចក្តីសុខខាងផ្លូវចិត្តនិងកាយ។យើងអាចនិយាយបានថាសាសនានិងនិកាយទាំងឡាយនៃសាសនាបានខិតខំអភិវឌ្ឍអត្តសញ្ញាណរបស់ខ្លួនដើម្បីសម្របសម្រួលបន្ថែមកង្វះខាតគ្នាទៅវិញទៅមកដើម្បីសេចក្តីសុខសាន្តត្រាណរបស់មនុស្សជាតិ។

ប្រសិនបើយើងមើលទៅសាសនាដោយទស្សនៈបែបនេះ យើងនឹងអាចយល់ឃើញថាសាសនាទាំងឡាយក្នុងលោកនេះមានចំណុចរួមដែលចងផ្ជាប់ជាមួយគ្នាមួយគឺសេចក្តីស្នេហាមេត្តាករុណាដែលណែនាំមនុស្សឱ្យចូលទៅរកភាពស្ងប់ស្ងាត់ខាងផ្លូវចិត្តនិងផ្លូវអារម្មណ៍។ហើយដោយសារតែការណែនាំជានិច្ចជាកាលពីសាសនាឱ្យយើងមានសេចក្តីស្រឡាញ់,មានចិត្តមេត្តាករុណានេះហើយទើបបានជា <សេចក្តីស្នេហានិងចិត្តមេត្តាករុណា> ដែលនៅស្ងៀមក្នុងជម្រៅចិត្តរបស់យើងម្នាក់ៗងើបឡើងហើយមិនអាចដេកស្ងៀមតទៅទៀតបានឡើយប្រសិនបើមិនបានប្រត្តិបត្តការងារ។បើនិយាយពីព្រះពុទ្ធសាសនា គឺការងារប្រតិបត្តវិធីរស់នៅបែបព្រះពោធិសត្វ។

ជួនកាលយើងមានអារម្មណ៍ថាគេខុសពីយើង ដូច្នេះមិនអាចមានសមានចិត្តចំពោះអ្នកដែលខុសពីខ្លួននោះបានឡើយ។នៅក្នុងខណៈបែបនេះបើយើងបំបែរក្រសែភ្នែករបស់យើងដែលបាញ់ឆ្ពោះសម្លឹងតែទៅរកអ្នកដទៃមកមើលចិត្តរបស់យើងម្តងវិញមើល,នៅពេលនោះយើងអាចនឹងទទួលយកបាននូវអ្វីដែលខុសពីយើងបានមិនខានឡើយ។

ពេលដែលខ្ញុំព្រះករុណាអាត្មាភាពចូលទៅរួមប្រជុំក្នុងសន្និសិទអន្តរជាតិម្តងៗហើយពើបប្រទះនឹងអ្នកដែលមានគំនិតខុសពីខ្លួនខ្ញុំព្រះករុណាអាត្មាភាពតែងតែមានអារម្មណ៍ថា <លោកអ្នកនេះមានគំនិតដែលអាត្មាភាពមិនដែលបានគិតដល់ ពិតជាគួរអោយគោរពណាស់។>

ឆ្លងកាត់តាមគំនិតដែលខុសពីគំនិតអាត្មាភាពនោះអាត្មាភាពអាចរៀនសូត្រចេះដឹងថាអាត្មាភាពនេះនៅមិនទាន់ចេះមិនទាន់ដឹងអ្វីច្រើនណាស់។ដូច្នេះជំនួសការបំប៉ោងសម្លេងចចេសថាគំនិតខ្លួនល្អប្រសើរហើយប្រឆាំងបដិសេធគំនិតអ្នកផ្សេងដែលខុសពីខ្លួន,មនុស្សយើងគួរតែទទួលយកនូវគំនិតដែលខុសពីខ្លួនសម្របសម្រួលគំនិតនោះជាមួយនឹងគំនិតយើងហើយបន្ទំគំនិតដែលបានប្រមូលផ្តុំចូលគ្នាឱ្យឡើងមូលនោះឱ្យបានទៅជាសេចក្តីសប្បាយរីករាយរួមគ្នានោះប្រាកដជានឹងបានសុភមង្គលមកខ្លួនយើងជាប្រាកដ។

នៅក្នុង <ព្រះធម៌ឱសថបុរាណ>  នៃព្រះត្រៃបទុមសូត្រមានវគ្គមួយចែងថា៖ <ធម្មទេសនានៃព្រះពុទ្ធអង្គពន្យល់នូវសមភាពគឺភាពស្មើៗគ្នា> ។ប្រសិនបើយើងគិតពីគោលបំណងរួមនៃសាសនាទាំងឡាយ ផ្គួបផ្សំជាមួយនឹងចិត្តដែលស្ថិតនៅជម្រៅបេះដូងរបស់យើងម្នាក់ៗយើងនឹងឃើញថា អាវកាសយានិកដែលជិះលើអាវកាសយានលេខផែនដីសុទ្ធតែបានទទួលនូវសេចក្តីសន្យាថាត្រូវតែមានសេចក្តីសុខនិងសុភមង្គលគ្រប់ៗគ្នា។ក្នុងន័យនេះអាវកាសយើងនេះក៏មានសមភាពដែរ។យើងម្នាក់ៗមានកាតព្វកិច្ចនឹងបញ្ជាក់នូវទ្រឹស្តីសមភាពនេះនៅក្នុងពិភពពិតប្រាកដដែលយើងរស់នៅសព្វថ្ងៃ។

(ទស្សនាវត្តីកូសេ លេខខែកញ្ញាឆ្នាំ២០១៩ )



# Rissho Kosei-kai: A Global Buddhist Movement




**Rissho Kosei-kai Buddhist Church of Hawaii**
2280 Auhuhu Street, Pearl City, HI 96782, USA
TEL: 1-808-455-3212FAX: 1-808-455-4633
Email: info@rkhawaii.org URL: http://www.rkhawaii.org

**Rissho Kosei-kai Maui Dharma Center**
1817 Nani Street, Wailuku, HI 96793, USA
TEL: 1-808-242-6175 FAX: 1-808-244-4625

**Rissho Kosei-kai Kona Dharma Center**
73-4592 Mamalahoa Highway, Kailua-Kona, HI 96740, USA
TEL: 1-808-325-0015 FAX: 1-808-333-5537

**Rissho Kosei-kai Buddhist Center of Los Angeles**
2707 East First Street, Los Angeles, CA 90033, USA
POBox 33636, CA 90033, USA
TEL: 1-323-269-4741 FAX: 1-323-269-4567
Email: rk-la@sbcglobal.net URL: http://www.rkina.org/losangeles.html

Please contact Rissho Kosei-kai Buddhist Center of Los Angeles
**Rissho Kosei-kai Buddhist Center of Arizona**
**Rissho Kosei-kai Buddhist Center of Colorado**
**Rissho Kosei-kai Buddhist Center of San Diego**
**Rissho Kosei-kai Buddhist Center of Las Vegas**
**Rissho Kosei-kai Buddhist Center of Dallas**

**Rissho Kosei-kai of San Francisco**
1031 Valencia Way, Pacifica, CA 94044, USA
POBox 778, Pacifica, CA 94044, USA
TEL: 1-650-359-6951 FAX: 1-650-359-6437
Email: info@rksf.org URL: http://www.rksf.org

Please contact Rissho Kosei-kai of San Francisco
**Rissho Kosei-kai of Sacramento**
**Rissho Kosei-kai of San Jose**

**Rissho Kosei-kai of New York**
320 East 39th Street, New York, NY 10016, USA
TEL: 1-212-867-5677 Email: rkny39@gmail.com URL: http://rk-ny.org

**Rissho Kosei-kai of Chicago**
1 West Euclid Ave., Mt. Prospect, IL 60056, USA
TEL: 1-773-842-5654
Email: murakami4838@aol.com URL: http://rkchi.org

**Rissho Kosei-kai of Fort Myers**
URL: http://www.rkftmyersbuddhism.org

**Rissho Kosei-kai Dharma Center of Oklahoma**
2745 N.W. 40th St., Oklahoma City, OK 73112, USA
POBox 57138, Oklahoma City, OK 73157, USA
TEL: 1-405-943-5030 FAX: 1-405-943-5303
Email: rkokdc@gmail.com URL: http://www.rkok-dharmacenter.org

**Rissho Kosei-kai Dharma Center of Denver**
1255 Galapago St. #809 Denver, CO 80204, USA
TEL: 1-303-446-0792

**Rissho Kosei-kai Dharma Center of Dayton**
617 Kling Drive, Dayton, OH 45419, USA
URL: http://www.rkina-dayton.com

**The Buddhist Center Rissho Kosei-kai International of North America (RKINA)**
2707 East First St., Suite #1, Los Angeles, CA 90033, USA
TEL: 1-323-262-4430 FAX: 1-323-262-4437
Email: info@rkina.org URL: http://www.rkina.org

**Rissho Kosei-kai Buddhist Center of San Antonio**
(Address) 6083 Babcock Road, San Antonio, TX 78240, USA
(Mail) POBox 692042, San Antonio, TX 78269, USA
TEL: 1-210-561-7991 FAX: 1-210-696-7745
Email: dharmasanantonio@gmail.com
URL: http://www.rkina.org/sanantonio.html

**Rissho Kosei-kai of Seattle's Buddhist Learning Center**
28621 Pacific Highway South, Federal Way, WA 98003, USA
TEL: 1-253-945-0024 FAX: 1-253-945-0261
Email: rkseattlewashington@gmail.com
URL: http://buddhistlearningcenter.org

**Rissho Kosei-kai of Vancouver**
Please contact RKINA

**Risho Kossei-kai do Brasil**
Rua Dr. José Estefno 40, Vila Mariana, São Paulo-SP, CEP 04116-060, Brasil
TEL: 55-11-5549-4446, 55-11-5573-8377
Email: risho@rkk.org.br URL: http://www.rkk.org.br

Facebook: https://www.facebook.com/rishokosseikaidobrasil
Instagram: https://www.instagram.com/rkkbrasil

**Risho Kossei-kai de Mogi das Cruzes**
Av. Ipiranga 1575-Ap 1, Mogi das Cruzes-SP, CEP 08730-000, Brasil

**在家佛教韓国立正佼成会**
〒 04420 大韓民国 SEOUL 特別市龍山區漢南大路 8 路 6-3
6-3, 8 gil Hannamdaero Yongsan gu, Seoul, 04420, Republic of Korea
TEL: 82-2-796-5571　FAX: 82-2-796-1696

**在家佛教韓国立正佼成会釜山支部**
〒 48460 大韓民国釜山廣域市南區水營路 174, 3F
3F, 174 Suyoung ro, Nam gu, Busan, 48460, Republic of Korea
TEL: 82-51-643-5571　FAX: 82-51-643-5572

**社團法人在家佛教立正佼成會**
台湾台北市中正區衡陽路 10 號富群資訊大厦 4 樓
4F, No. 10, Hengyang Road, Jhongjheng District, Taipei City 100, Taiwan
TEL: 886-2-2381-1632, 886-2-2381-1633　FAX: 886-2-2331-3433

**台南市在家佛教立正佼成會**
台湾台南市崇明 23 街 45 號
No. 45, Chongming 23rd Street, East District, Tainan City 701, Taiwan
TEL: 886-6-289-1478　FAX: 886-6-289-1488
Email: koseikaitainan@gmail.com

**Rissho Kosei-kai South Asia Division**
Thai Rissho Friendship Foundation
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang, Bangkok 10310, Thailand
TEL: 66-2-716-8216　FAX: 66-2-716-8218

**Rissho Kosei-kai of Kathmandu**
Ward No. 3, Jhamsikhel, Sanepa-1, Lalitpur, Kathmandu, Nepal

**Rissho Kosei-kai of Kolkata**
E-243 B. P. Township, P. O. Panchasayar, Kolkata 700094, India

**Rissho Kosei-kai of Kolkata North**
AE/D/12 Arjunpur East, Teghoria, Kolkata 700059, West Bengal, India

**Rissho Kosei-kai of Bodhgaya Dharma Center**
Ambedkar Nagar, West Police Line Road, Rumpur, Gaya-823001,
Bihar, India

**Rissho Kosei-kai of Patna Dharma Center**

**Rissho Kosei-kai of Central Delhi**
77 Basement D.D.A. Site No. 1, New Rajinder Nagar,
New Delhi 110060, India

**Rissho Kosei-kai of Singapore**

**Rissho Kosei-kai of Phnom Penh**
W.C. 73, Toul Sampaov Village, Sangkat Toul Sangke, Khan Reouseykeo,
Phnom Penh, Cambodia

**RKISA Rissho Kosei-kai International of South Asia**
Thai Rissho Friendship Foundation
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang, Bangkok 10310, Thailand
TEL: 66-2-716-8141　FAX: 66-2-716-8218

**Rissho Kosei-kai of Bangkok**
Thai Rissho Friendship Foundation
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang, Bangkok 10310, Thailand
TEL: 66-2-716-8216　FAX: 66-2-716-8218　Email: info.thairissho@gmail.com

**Rissho Kosei Dhamma Foundation**
No. 628-A, Station Road, Hunupitiya, Wattala, Sri Lanka
TEL: 94-11-2982406　FAX: 94-11-2982405

**Rissho Kosei-kai of Polonnaruwa**

**Rissho Kosei-kai Bangladesh**
85/A Chanmari Road, Lalkhan Bazar, Chittagong, Bangladesh
TEL/FAX: 880-31-626575

**Rissho Kosei-kai Mayani**
Mayani Barua Para, Mirsarai, Chittagong, Bangladesh
**Rissho Kosei-kai Damdama**
Damdama Barua Para, Mirsarai, Chittagong, Bangladesh
**Rissho Kosei-kai Patiya**
China Clinic, Patiya Sadar, Patiya, Chittagong, Bangladesh

**Rissho Kosei-kai Satbaria**
Village: Satbaria Bepari Para, Chandanaih, Chittagong, Bangladesh

**Rissho Kosei-kai Chendhirpuni,**
Village: Chendhirpuni, P.O.: Adhunogar, P.S.: Lohagara, Chittagong,
Bangladesh

**Rissho Kosei-kai Dhaka**
408/8 DOSH, Road No 7 (West), Baridhara, Dhaka, Bangladesh

**Rissho Kosei-kai Laksham**
Village: Dhupchor, Laksham, Comilla, Bangladesh

**Rissho Kosei-kai Cox's Bazar**
Ume Burmize Market, Tekpara, Sadar, Cox's Bazar, Bangladesh

**Rissho Kosei-kai Cox's Bazar, Ramu Shibu**

**Rissho Kosei-kai Raozan**
Dakkhin Para, Ramzan Ali Hat, Raozan, Chittagong, Bangladesh

**Buddiyskiy khram "Lotos"**
4 Gruzinski Alley, Yuzhno-Sakhalinsk 693005, Russia
TEL: 7-4242-77-05-14

**Rissho Kosei-kai of Hong Kong**
Flat D, 5/F, Kiu Hing Mansion, 14 King's Road, North Point, Hong Kong, China

**Rissho Kosei-kai Friends in Shanghai**

**Rissho Kosei-kai of Ulaanbaatar**
(Address) 15F Express Tower, Peace avenue, khoroo-1, Chingeltei district,
Ulaanbaatar 15160, Mongolia
(Mail) POBox 1364, Ulaanbaatar-15160, Mongolia
TEL: 976-70006960　Email: rkkmongolia@yahoo.co.jp

**Rissho Kosei-kai of Erdenet**
2F Ikh Mandal building, Khurenbulag bag, Bayan-Undur sum,
Orkhon province, Mongolia

**Rissho Kosei-kai di Roma**
Via Torino, 29, 00184 Roma, Italia
TEL/FAX: 39-06-48913949　Email: roma@rk-euro.org

**Rissho Kosei-kai of the UK**
**Rissho Kosei-kai of Paris**
**Rissho Kosei-kai of Venezia**

**Rissho Kosei-kai International Buddhist Congregation (IBC )**
166-8537 東京都杉並区和田 2-7-1 普門メディアセンター 3F
Fumon Media Center 3F, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan
TEL: 03-5341-1230　FAX: 03-5341-1224　URL: http://www.ibc-rk.org

**Published by Rissho Kosei-kai International**